# មេធាវីការពារក្តីប្រឆាំងជំទាស់នឹងការដាក់ជូននូវចម្លើយសាក្សី ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់

***ដោយ អែន ហេនខែល, ទីប្រឹក្សាច្បាប់ មជ្ឈមណ្ឌលឯកសារកម្ពុជា***

***ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២***

*ប្រែសម្រួលដោយ វ៉ាន់ថាន់ ពៅដារ៉ា*

សហព្រះរាជអាជ្ញាកំពុងស្វែងរកការដាក់នូវចម្លើយសាក្សីចំនួន ១៣៥០ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ និងការសួរដេញដោលផ្ទាល់ក្នុងតុលាការក្នុងសំណុំរឿង ០០២/០១ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ចម្លើយសាក្សីប្រមាណ ៤០០ ក្នុងចំណោមចំនួនខាងលើត្រូវបានធ្វើឡើងដោយស្ថាប័នមិនមែនតុលាការ នៅមុនពេលដែលអង្គជំនុំជម្រះបានចាប់ផ្តើមដំណើរការ ។[១] សហព្រះរាជអាជ្ញានិយាយថា សំណើសុំរបស់ខ្លួន[២]នឹងជួយដល់ការចាត់ចែងរឿងក្តីព្រហ្មទណ្ឌធ្ងន់ធ្ងរ និងការស្វែងរកការពិតឲ្យកាន់តែមានប្រសិទ្ធិភាព ។ ក្រុមមេធាវីការពារក្តីបានប្រឆាំងជំទាស់នឹងសំណើនេះ ដោយចោទថារំលោភនឹងសិទ្ធិទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ ។ ថ្មីៗនេះ ក្រុមមេធាវីការពារក្តី នួន ជា បានប្តឹងជំទាស់ដោយអះអាងថា ចំនួនដ៏សន្ធឹកសន្ធាប់នៃចម្លើយសាក្សីនៅក្នុងបញ្ហានេះ ប្រភេទនៃព័ត៌មាននៅក្នុងចម្លើយសាក្សី ហើយទាក់ទងនឹងចម្លើយសាក្សីដែលប្រមូលដោយស្ថាប័នដែលមិនមែនតុលាការ ការខ្វះការបញ្ជាក់ជាផ្លូវការ គឺវាមិនស្របនឹងការអនុវត្តជាអន្តរជាតិដែលជ្រោមជ្រែងពីមុនៗមកដោយអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

---

[១] ឧទាហរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានប្រមូលចងក្រងឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលធ្វើឡើងដោយ និងទាក់ទងនឹងរបបខ្មែរក្រហម“បានសម្ភាសកម្មាភិបាលខ្មែរក្រហម និងសមាជិកគ្រួសាររបស់អ្នកទាំងនោះ រួមទាំងជនរងគ្រោះ ជាង១ម៉ឺននាក់នៅទូទាំងប្រទេស”រវាងឆ្នាំ២០០០ ដល់២០០៧ ។ មជ្ឈមណ្ឌលឯកសារ“បានចាប់ផ្តើមពិនិត្យប្រវត្តិរូបរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងសំណុំឯកសាររបស់ខ្លួន ដើម្បីរកឈ្មោះកន្លែងកំណើត និងព័ត៌មានមូលដ្ឋានផ្សេងទៀតទាក់ទិននឹងអតីតកម្មភិបាលខ្មែរក្រហមរាប់ពាន់នាក់ ។ ក្រុមស្រាវជ្រាវបានធ្វើដំណើរពីខេត្តមួយទៅខេត្តមួយទៀតដើម្បីស្វែងរកនិងសម្ភាសអ្នកទាំងនោះ” ។ ការរៀបរាប់អំពីគម្រោងជំរុញឲ្យមានការទទួលខុសត្រូវអាចរកបានតាម http://www.d.dccam.org/Projects/Promoting/Promoting_Accountability.htm

[២] សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ក្នុងការដាក់នៅចំពោះអង្គជំនុំជម្រះនូវប្រតិចារិក និងចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ វាក្យខណ្ឌ ៣ (ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២) ។ *សូមមើល* អត្ថាធិប្បាយអ្នកជំនាញស្តីអំពីការដាក់ឯកសារច្បាប់ ៖ ការទទួលយកបាននៃចម្លើយសាក្សីជំនួសឲ្យសក្ខីយកម្មផ្ទាល់មាត់ *អាចរកបានតាម* http://www.cambodiatribunal.org/blog/2012/07/expert-commentary-legal fillings-admissibility-witness-statements-lieu-oral-testimony ។

កាលពីខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំសុំកិច្ចប្រជុំ ស្នើសុំតាមស្នើរកការដាក់ជូននូវចម្លើយសាក្សី និងកំណត់ត្រាការស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ។ ដោយយល់ថា មានការខ្វះខាតនូវវិធានដែលអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអនុញ្ញាតឲ្យមាន ការអនុវត្តបែបនេះ សហព្រះរាជអាជ្ញាលើកឡើងថា «អង្គជំនុំជម្រះសាលាដំបូង គួរតែស្វែងរកការ ណែនាំពីវិធានផ្សេងៗដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ហើយច្នៃវិធានទាំងនោះឲ្យស្របនឹងនីតិវិធី ដែលអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។[៣] កាលពីខែមិថុនា ឆ្នាំ២០១២ អង្គជំនុំ ជម្រះសាលាដំបូងបានសម្រេចលើសំណើសុំនោះ ។ អង្គជំនុំជម្រះ សម្រេចថា ខ្លួនមាន«ឆន្ទានុសិទ្ធិទូលំ ទូលាយ» ក្នុងការពិចារណារាល់ភស្តុតាងទាំងអស់ដែលពាក់ព័ន្ធ និងអាចបំភ្លឺផ្លូវដែលបានដាក់នៅចំពោះ មុខខ្លួននិងអនុញ្ញាតដោយវិធាន៨៧(៣)ក្នុងការបដិសេធរាល់ភស្តុតាងដែល ៖

ក) មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា

ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ

គ) មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ) ច្បាប់មិនអនុញ្ញាត ឬ

ង) មានចេតនាពន្យារពេលកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍ ។

ដោយកំណត់ថា សិទ្ធិរបស់ជនជាប់ចោទក្នុងការសួរដេញដោលតទល់គ្នាមិនមែនជាសិទ្ធិដាច់មុខ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វិធានមួយចំនួនដែលតុលាការអន្តរជាតិអនុញ្ញាតឲ្យមានការដាក់ ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ ដោយពុំមានការសួរដេញដោលតទល់គ្នា ធ្វើឲ្យប៉ះពាល់ដល់«តុល្យ ភាពសមស្របរវាងសិទ្ធិរបស់ចុងចោទក្នុងការទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ និងប្រសិទ្ធិភាព នីតិវិធី» នៅក្នុងបុព្វបទនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។[៤]

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (អាយ.ស៊ី.ធី.វ៉ាយ) និងរ៉ាន់ដា អនុញ្ញាតឲ្យមានការដាក់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ដែល«នឹងបង្ហាញ

---

[៣] សំណើរបស់សហព្រះរាជអាជ្ញាតាមវិធាន ៩២ ទាក់ទិននឹងការទទួលយកបាននូវចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ឯកសារ ៣៥ (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១) (ជាបន្តទៅមុខត្រូវបានហៅថា សំណើរបស់សហព្រះរាជអាជ្ញាតាមវិធាន ៩២) ។

[៤] សេចក្តីសម្រេចស្តីពីសំណើរបស់សហព្រះរាជអាជ្ញាតាមវិធាន ៩២ ទាក់ទិននឹងការទទួលយកបាននូវចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ឯកសារ ១៧, ២០ (ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២) (ជាបន្តទៅមុខត្រូវបានហៅថា សេចក្តីសម្រេចថ្ងៃទី២០ ខែមិថុនា) ។

អំពីអង្គហេតុជាជាងបង្ហាញអំពីអំពើនិងការប្រព្រឹត្តរបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ» ។ ឧទាហរណ៍ វិធាន៩២ស្ទួន របស់ អាយ.ស៊ី.ធី.វ៉ាយ កំណត់បញ្ជីនៃកត្តាមួយចំនួនដែលគាំទ្រដល់ និងប្រឆាំងនឹងការស្នើសុំ ។ អនុវិធាន (ខ) កំណត់នូវទម្រង់មួយចំនួនដែលតម្រូវ ប្រសិនបើការស្នើសុំឲ្យទទួលយកឯកសារ ត្រូវបានទទួលយកទៅធ្វើការពិចារណាដោយសមស្រប រួមមានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយសាក្សីដែលខ្លឹមសារនៃចម្លើយរបស់ខ្លួន គឺពិត និងត្រឹមត្រូវហើយសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរពីសំណាក់សាក្សីដែលទទួលបានការអនុញ្ញាតយ៉ាងត្រឹមត្រូវមានការបញ្ជាក់ពីស្ថានភាពផ្សេងៗដែលចម្លើយសាក្សីត្រូវបានធ្វើឡើងហើយអនុវិធាន(គ) ចែងថា ក្រោយពីស្តាប់ទឡ្ហីករណ៍របស់គូភាគីទាក់ទងនឹងកត្តាមួយចំនួនដែលមានក្នុងបញ្ជីនៃអនុវិធាន(ក) អង្គជំនុំជម្រះនឹងសម្រេចថា តើត្រូវតម្រូវ ឬមិនតម្រូវឲ្យសាក្សីមកបង្ហាញខ្លួននៅចំពោះតុលាការសម្រាប់ការសួរដេញដោលតទល់គ្នាលើចម្លើយរបស់សាក្សីនោះ ។

ក្រុមមេធាវីការពារក្តី នួន ជា លើកហេតុផលថា ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រេចយកកត្តាមួយចំនួនដើម្បីធ្វើការថ្លឹងថ្លែងទាំងលើការគាំទ្រ ទាំងលើការជំទាស់ការស្នើសុំឲ្យទទួលយកឯកសារតាមវិធាន ៩២ស្ទួន (ក)របស់ អាយ.ស៊ី.ធី.វ៉ាយ នោះ ខ្លួនត្រូវអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការកម្រិតក្នុងអនុវិធាន (ខ) និង (គ)ដោយសារថាអនុវិធានទាំងនេះ «គឺជាចំណុចស្នូលនៅក្នុងរបបគតិយុត្តិ ដែលមានគោលដៅធ្វើឲ្យដំណើរការមានការប្រទាក់ក្រឡាគ្នាក្នុងការអនុវត្ត» ។ ក្រុមមេធាវីនេះនិយាយថា ប្រសិនបើការកម្រិតទាំងនេះ នឹងត្រូវយកមកអនុវត្តមែននោះ ចម្លើយសាក្សីរបស់សហព្រះរាជអាជ្ញាស្ទើរតែទាំងអស់នឹងត្រូវច្រានចោលជាមិនខាន ។[៥]

ក្រុមមេធាវីនេះសង្កត់ធ្ងន់ថាតាមដែលខ្លួនដឹងគ្មាននីតិវិធីអន្តរជាតិសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរណាមួយទទួលយល់ព្រមលើសក្ខីកម្មលាយលក្ខណ៍អក្សរធ្វើជាភស្តុតាង ដូចនឹងទំហំដែលប្រហាក់ប្រហែលនឹងសំណើសុំរបស់សហព្រះរាជអាជ្ញានោះទេ ។ ឧទាហរណ៍ ក្រុមមេធាវីនេះនិយាយថា ខ្លួនពុំបានរកឃើញរឿងក្តីព្រហ្មទណ្ឌអន្តរជាតិណាមួយដែលភាគីមួយ «ស្វែងរកការដាក់ជូននូវចម្លើយសាក្សីបែបនេះ ច្រើនជាង ១៣០ នៅក្នុងសំណើសុំមួយនោះទេ» ។ ខ្លួនអះអាងថា បែបបទនៅក្នុងវិធាន ៩២ស្ទួន របស់ អាយ.ស៊ី.ធី.វ៉ាយ ដែលប្រមើមើលពីការកំណត់ទទួលយកភស្តុតាងក្រោមអនុវិធាន(ក) គឺអនុវត្តតាមយ៉ាងខ្ជាប់ខ្ជួនដោយមានការសួរដេញដោលតទល់គ្នាតាមអនុវិធាន (គ) ដែល «បង្ហាញឲ្យឃើញថា អ្នកធ្វើសេចក្តីព្រាងពុំបានគិតដល់សំណើឲ្យមានការទទួលយកចម្លើយសាក្សីច្រើនបែបនេះ ដោយមិនកោះ

---

[៥] ការឆ្លើយតបបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ក្នុងការដាក់នៅចំពោះអង្គជំនុំជម្រះនូវប្រតិចារិក និងចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ វាក្យខណ្ឌ ៥ (ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២) ។

ហៅសាក្សីផ្ទាល់ឲ្យមកធ្វើសក្ខីកម្មនោះទេ» ។ ខ្លួនអះអាងថា ភាពមិនអាចឲ្យមានការសួរដេញដោលតទល់គ្នា គឺជាផលវិបាកដែលមិនអាចជៀសវាងបាននៃ«ចំនួនឯកសារភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ដែលមិនធ្លាប់មានពីមុនមក» ដែលខាងសហព្រះរាជអាជ្ញាព្យាយាមដាក់បញ្ចូល ។[៦]

ក្រុមមេធាវីការពារក្ដីជំទាស់ជាបន្ថែមលើខ្លឹមសារនៃចម្លើយសាក្សី ដែលសហព្រះរាជអាជ្ញាព្យាយាមស្នើសុំ ដោយអះអាងថា ខ្លឹមសារជាច្រើនគឺមិនអាចទទួលយកបានទេ បើយោងតាមការអនុវត្តនៅ អាយ.ស៊ី.ធី.វ៉ាយ ពីព្រោះការសួរដេញដោលតទល់គ្នាគឺចាំបាច់ចំពោះចម្លើយសាក្សីដែលនឹងត្រូវប្រើសម្រាប់«អំពើល្មើសដែលនៅជិតបំផុតនឹងជនជាប់ចោទ» ឬ«បញ្ហាជាក់ស្ដែងរវាងភាគី...» ។ លើសពីនេះទៀត ក្រុមមេធាវីនេះនិយាយថា ផ្នែកខ្លះនៃចម្លើយសាក្សីគឺពុំអាចនិយាយ ដល់អំពើ ឬការប្រព្រឹត្តរបស់ជនជាប់ចោទ និងថាដោយហេតុផលដូច្នេះគឺមិនអាចទទួលយកបាន ដោយគ្មានការកាត់តែងសេចក្ដីដែលស៊ីពេលវេលាយ៉ាងច្រើននោះទេ ។[៧]

ទាក់ទងនឹងចម្លើយសាក្សី ដែលធ្វើឡើងដោយស្ថាប័នដែលនៅក្រៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចជាអង្គការក្រៅរដ្ឋាភិបាល និងអ្នកស្រាវជ្រាវ ក្រុមមេធាវី នួន ជា អះអាងថាចម្លើយសាក្សីក្នុងប្រភេទនេះទាំងអស់គឺមិនអាចទទួលយកបានទេ ពីព្រោះមិនឆ្លើយតបបាននឹងលក្ខខណ្ឌតម្រូវដែលបញ្ជាក់ជាផ្លូវការតាមវិធាន៩២ស្ទួន(ខ) ។[៨]

---

[៦] ស្ទួន, វាក្យខណ្ឌ ៣, ៩ ជើងទំព័រ ១៨ ។

[៧] ស្ទួន, វាក្យខណ្ឌ ១២, ១៥, ១៨-២២ ។ *សូមមើល* រាជអាជ្ញា ប្រឆាំងនឹង ភេរីសិក, សំណុំរឿងព្រហ្មទណ្ឌលេខ IT-04-81-T សេចក្ដីសម្រេចស្ដីពីសំណើសុំរបស់ព្រះរាជអាជ្ញាសម្រាប់ឲ្យទទួលយកភស្ដុតាង អនុលោមតាមវិធាន៩២ ស្ទួន, វាក្យខណ្ឌ១២, ១៤ (អង្គជំនុំជម្រះ, ថ្ងៃទី២ ខែតុលា ឆ្នាំ២០០៨) (ទាក់ទិននឹង "ភាពនៅជិតបំផុតនឹងជនជាប់ចោទ" ឬ«បញ្ហាជាក់ស្ដែងរវាងភាគី») ។

[៨] ការឆ្លើយបតបឋម, វាក្យខណ្ឌ ៤០, ៤៦ ។ វិធាន ៩២ ស្ទួន(ខ) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចែងយ៉ាងពេលលេញ ៖ ប្រសិនបើអង្គជំនុំជម្រះសម្រេចមិនចាំបាច់ឲ្យមានវត្តមានសាក្សីក្នុងសវនាការ ចម្លើយលាយលក្ខណ៍តាមវិធាននេះត្រូវទទួលយកបានប្រសិនបើចម្លើយនេះមានភ្ជាប់មកជាមួយនូវសេចក្ដីប្រកាសរបស់អ្នក ដែលផ្ដល់ចម្លើយដែលខ្លឹមសារនៃចម្លើយគឺ ពិត និងត្រឹមត្រូវតាមការយល់ដឹង និងការជឿជាក់របស់អ្នកផ្ដល់នោះ និង

(១) សេចក្ដីប្រកាសនេះធ្វើឡើងនៅចំពោះមុខ ៖

(ក) អ្នកដែលទទួលការអនុញ្ញាតឲ្យធ្វើសាក្សីចំពោះសេចក្ដីបែបនេះ ដោយអនុលោមតាមច្បាប់ និងនីតិវិធីរបស់រដ្ឋនោះ ឬ

(ខ) មន្ត្រីអធិបតីដែលតែងតាំងដោយនាយកក្រឡាបញ្ជីរបស់តុលាការសម្រាប់គោលបំណងនោះ

(២) អ្នកដែលធ្វើជាសាក្សីលើសេចក្ដីប្រកាសបញ្ជាក់អះអាងជាលាយលក្ខណ៍អក្សរ ៖

(ក) ថាអ្នកដែលផ្ដល់ចម្លើយគឺជាអ្នកដែលមានអត្តសញ្ញាណនៅក្នុងចម្លើយនោះ

(ខ) ថាអ្នកដែលផ្ដល់ចម្លើយបានថ្លែងថា ខ្លឹមសារចម្លើយលាយលក្ខណ៍អក្សរគឺពិត និងត្រឹមត្រូវតាមការយល់ដឹង និងការជឿជាក់របស់ខ្លួន

អនុវិធាននេះ«ចែងពីរបៀបដែលខ្លឹមសារនៃចម្លើយ សាក្សីត្រូវតែអាចបញ្ជាក់ថាត្រឹមត្រូវដោយសាក្សីខ្លួនឯង»[៩] ។ សេចក្តីប្រកាសរបស់សាក្សីគឺបម្រើនូវបំណងដូចគ្នានឹង«សេចក្តីបញ្ជាក់ផ្ទាល់មាត់របស់សាក្សី ប្រសិនបើសាក្សីនោះមានវត្តមាននៅក្នុងបន្ទប់សវនាការ»[១០] ហើយថា «ភាគីទាំងអស់មិនត្រូវបានកម្រិតក្នុងការធានាការបញ្ជាក់ឲ្យពិតប្រាកដ ដោយមន្ត្រីដែលចាត់ឲ្យធ្វើការងាររបស់តុលាការនោះទេ ក៏ប៉ុន្តែសេចក្តីប្រកាសនោះត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ និងនីតិវិធីរបស់រដ្ឋមួយ»[១១] ។ យោងតាមយុត្តិសាស្ត្ររបស់តុលាការអាយ.ស៊ី.ធី.វ៉ាយ ទម្រង់បែបបទរបៀបនេះ គឺត្រូវតែធ្វើ គឺថា «វាគឺអាចអនុញ្ញាតបានសម្រាប់អង្គជំនុំជម្រះក្នុងការទទួល យកការផ្តល់នូវចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ តាមវិធាន ៩២ស្ទួន លុះត្រាណាបានបញ្ចប់តាមលក្ខខណ្ឌផ្លូវការតាមវិធាន ៩២ស្ទួន(ខ), ផ្ទុយទៅវិញ ចម្លើយសាក្សីមិនទទួលបាននូវការអនុញ្ញាតពេញលេញ ប្រសិនបើមិនបំពេញបានតាមលក្ខខណ្ឌតម្រូវ»[១២] ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ នៅមានការ លើកលែងក្នុងការទទួលយកចម្លើយសាក្សីរបស់អ្នកដែលរកមិនឃើញប្រសិនបើតុលាការ «យល់ឃើញថា ក្នុងកាលៈទេសៈណាមួយដែលចម្លើយសាក្សីត្រូវបានធ្វើឡើង និងកត់ត្រានោះគឺពិតជាគួរឲ្យជឿទុក ចិត្តបាន»[១៣] ។

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអះអាងបញ្ជាក់ថា ចម្លើយសាក្សីដែលប្រមូលបានមកពីការស៊ើបអង្កេតក្រៅប្រពន្ធ័តុលាការ គឺ«មានសុចនករយ៉ាងរឹងមាំដែលគួរឲ្យជឿទុកចិត្តបាន» ក៏ប៉ុន្តែកត់សម្គាល់ថា អង្គជំនុំជម្រះអាចពិចារណាទី១ «ថាតើការបញ្ជាក់ដូច ដែលមានចែងក្នុងអនុវិធាន៩២ស្ទួន(ខ) គឺសមស្របឬមិនសមស្រប», ទី២ «ចម្លើយសាក្សីអាចទទួលយក

---

(ក) ថាអ្នកដែលផ្តល់ចម្លើយត្រូវបានប្រាប់ថា ប្រសិនបើខ្លឹមសារនៃចម្លើយលាយលក្ខណ៍អក្សរមិនពិតនោះ អ្នកផ្តល់ចម្លើយនឹងប្រមុខនឹងច្បាប់ចំពោះការផ្តល់សក្ខីកម្មក្លែងក្លាយ និង

(ឃ) កាលបរិច្ឆេទ និងទីកន្លែងនៃសេចក្តីប្រកាស ។

[៩] រដ្ឋអាជ្ញាប្រឆាំងនឹង ការាឌីក, សំណុំរឿងព្រហ្មទណ្ឌលេខ **IT-95-5/18-T,** សេចក្តីសម្រេចស្តីពីសំណើរបស់ជនជាប់ចោទសុំឲ្យទទួលយកចម្លើយបន្ថែមរបស់សាក្សី **KDZ407,** វាក្យខណ្ឌ ១ (អង្គជំនុំជម្រះ ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១២ ។

[១០] រដ្ឋអាជ្ញាប្រឆាំងនឹងស.ម៉ីឡូសេវិច, សំណុំរឿងព្រហ្មទណ្ឌលេខ **IT-02-54-AR73.4,** យោបល់ដោយឡែករបស់ចៅក្រម ហ្សាហាបុឌីន ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីភាពអាចទទួលយកបាននូវភស្តុតាងក្នុងទម្រង់ជាចម្លើយលាយលក្ខណ៍អក្សរ, វាក្យខណ្ឌ ៧ (អង្គជំនុំជម្រះឧទ្ធរណ៍, ថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០០៣) ។

[១១] រដ្ឋអាជ្ញាប្រឆាំងនឹងណីរាបាត់វ៉ៃ, សំណុំរឿងព្រហ្មទណ្ឌលេខ **ICTR-99-54-T,** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំឲ្យសម្រេចទទួលយកចម្លើយលាយលក្ខណ៍អក្សរ និងសុំឲ្យមានលិខិតបញ្ជាក់លើចម្លើយលាយលក្ខណ៍អក្សររបស់មន្ត្រីអធិបតី, វាក្យខណ្ឌ ២២ (អង្គជំនុំជម្រះ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១) ។

[១២] សំណុំរឿងព្រហ្មទណ្ឌ ការាឌីក, វាក្យខណ្ឌ ៥ ។

[១៣] វិធាន ៩២ ស្ទួន របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។

បានឬមិនបានប្រសិនបើសាក្សីរូបនោះបានស្លាប់ទៅហើយឬមិនអាចទៅរកឃើញតាមលទ្ធភាពដ៏សមរម្យដែលបានធ្វើរួចហើយ» ឬទី៣ ថាតើ«ចម្លើយសាក្សីដែលទទួលយកតាមការផ្តល់ជូនគឺតម្រូវឲ្យមានការបញ្ជាក់ ឬមិនតម្រូវទេ» ដូចជាតាមរយៈការសុំឲ្យ«មានការបញ្ជាក់ពីអ្នកស្រាវជ្រាវលើកាលៈទេសៈដែលចម្លើយសាក្សីនោះត្រូវបានធ្វើឡើង ឬតម្រូវឲ្យមានការបង្ហាញបន្ថែមទៀតលើភាព ដែលអាចជឿទុកចិត្តបាន ដូចជាកំណត់ត្រាដែលធ្វើឡើងនៅពេលយកចម្លើយសាក្សី ឬការថតសំឡេង» ។[១៤]

កន្លងមក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចតែម្យ៉ាងថា ចម្លើយសាក្សីដែលមិនប្រមូលក្រោមការត្រួតពិនិត្យមើលពីតុលាការ «គឺមិនទទួលបាននូវការសន្មត់ថា មានភាពដែលគួរឲ្យជឿទុកចិត្តបាន» ។[១៥] ទន្ទឹមនឹងគ្នានេះដែរ អង្គជំនុំជម្រះបាននិយាយថា ខ្លួននឹងយល់ព្រមទទួលយកចម្លើយសាក្សីបែបនេះ ដោយរួមមានសុចនករនៃភាពដែលគួរជឿទុកចិត្តបាន ។[១៦] ឥឡូវនេះ អង្គជំនុំជម្រះនឹងត្រូវសម្រេចថាតើទម្រង់បែបបទតាមវិធាន៩២ស្ទួនរបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ គួរត្រូវយកមកអនុវត្តនៅក្នុងនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬមិនគួរ(ដោយប្រានចោលដាច់ខាតនូវចម្លើយសាក្សីដ៏ច្រើនក្រាស់ក្រែលដែលបានមកពីស្ថានបន័ដែលមិនមែនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ថាតើត្រូវជ្រើសរើសយកតែបទសម្ភាសន៍ដែលកំណត់បានថា សាក្សីនោះអាចមកធ្វើការសួរដេញដោលតទល់គ្នាបានឬក៏ទទួលយកនូវការបង្ហាញតាមជម្រើសណាមួយដែលអាចមានភាពគួរឲ្យជឿទុកចិត្តបាន ។ តាមជម្រើសមួយណាក៏ដោយ អង្គជំនុំជម្រះប្រាកដជាប្រឈមនឹងភារកិច្ចដ៏អស្ចារ្យមួយក្នុងការវាយតម្លៃលើចំនួនឯកសារដ៏ច្រើនលើសលប់នីមួយៗដែលមាននៅចំពោះមុខដោយអនុលោមតាមការអនុវត្តជាអន្តរជាតិជាក់ជាមិនខាន ។

---

[១៤] សំណើរបស់សហព្រះរាជអាជ្ញាស្តីពីវិធាន ៩២ ស្ទួន, វាក្យខណ្ឌ ៣៩-៤០ ។

[១៥] តាមការកត់សម្គាល់ អង្គជំនុំជម្រះសាលាដំបូងបានបែងចែកយ៉ាងជាក់លាក់នូវឯកសារនាសម័យខ្មែរក្រហមដែលប្រមែប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបាន«ការសន្មត់ទុកថាមានការពាក់ព័ន្ធ និងជឿទុកចិត្តបាន រួមទាំងយថាភាពផង ដោយមានការពិនិត្យលើគោលនយោបាយ និងការអនុវត្តបណ្ណសាររបស់ខ្លួន», សេចក្តីសម្រេចថ្ងៃទី២០ ខែមិថុនា, វាក្យខណ្ឌ២៩ ជើងទំព័រ ៤៨ ។

[១៦] ស្ទួន, វាក្យខណ្ឌ ២៩ ។